ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៣៩០០ មស.សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបោះពុម្ពតារាងទូទាត់បៀវត្ស អាណត្តិបើកប្រាក់ និងការបើកផ្តល់បៀវត្ស ជូនមន្ត្រីរាជការស៊ីវិលសម្រាប់ខែតុលា-វិច្ឆិកា ឆ្នាំ២០១៨

យោងសារាចរលេខ ០១ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល ។

ក្រសួងមុខងារសាធារណៈ មានកិត្តិយស សូមគោរពជម្រាបជូនសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត លោក លោកស្រីប្រធានមន្ទីរ និងអង្គភាពចំណុះមេត្តាជ្រាបថា ក្នុងគោលបំណងចូលរួមអនុវត្តឱ្យបានសម្រេចនូវខ្លឹមសារនៃសារាចរ ដូចមានយោងខាងលើ និងគោលការណ៍ថ្មីៗរបស់រាជរដ្ឋាភិបាល ឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងមុខងារសាធារណៈ សូមដាក់ចេញនូវសេចក្តីជូនដំណឹងសម្រាប់សហការអនុវត្តដូចខាងក្រោម ៖

- សម្រាប់បៀវត្សប្រចាំខែតុលា ឆ្នាំ២០១៨ ក្រសួងមុខងារសាធារណៈ សូមស្នើសុំគ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពចំណុះ ពុំចាំបាច់ស្នើសុំបម្រែបម្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារទេ លើកលែងករណីផ្ទេរក្របខ័ណ្ឌ និងរៀបបៀវត្សមន្ត្រីថ្មី ដោយត្រូវផ្តល់ឯកសារមកក្រសួងមុខងារសាធារណៈ យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨ ។
- ក្រសួងមុខងារសាធារណៈ នឹងរៀបចំបោះពុម្ពតារាងទូទាត់បៀវត្សខែតុលា ឆ្នាំ២០១៨ ដោយផ្អែកលើទិន្នន័យដែលមានក្នុងតារាងទូទាត់បៀវត្សរបស់មន្ត្រីរាជការស៊ីវិលប្រចាំខែកញ្ញា ឆ្នាំ២០១៨ជាគោល និងធ្វើការរៀបចំទិន្នន័យផ្តល់ប្រាក់ឧបត្ថម្ភផ្សេងទៀតជូនដល់មន្ត្រីរាជការ ដោយស្វ័យប្រវត្តិទៅតាមគោលការណ៍របស់រាជរដ្ឋាភិបាល ។
- គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវធានាការបើកផ្តល់បៀវត្សប្រចាំខែតុលា ឆ្នាំ២០១៨ ជូនមន្ត្រីរាជការស៊ីវិលរបស់ខ្លួន ឱ្យបានមុនថ្ងៃបុណ្យភ្ជុំបិណ្ឌ ។
- សម្រាប់ការបើកផ្តល់បៀវត្សប្រចាំខែវិច្ឆិកា ឆ្នាំ២០១៨ គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវស្នើសុំបម្រែបម្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារ (សម្រាប់តែករណីក្របខ័ណ្ឌថ្មី ផ្ទេរក្របខ័ណ្ឌ តែងតាំង សម្រួលភារកិច្ច និងមន្ត្រីដែលផ្តាច់បៀវត្ស) មកក្រសួងមុខងារសាធារណៈ ត្រឹមសប្តាហ៍ទី២ នៃខែតុលា ឆ្នាំ២០១៨ ដើម្បីធានាការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិលរបស់ខ្លួនឱ្យបានក្នុងសប្តាហ៍ទី២ នៃខែវិច្ឆិកា ឆ្នាំ២០១៨ ។

ក្រសួងមុខងារសាធារណៈ សង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃក្រសួង ស្ថាប័ន ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត លោក លោកស្រីប្រធានមន្ទីរ និងអង្គភាពចំណុះ នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ តាមការគួរ ។

ថ្ងៃ សុក្រ ១២កើត ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១៨
រដ្ឋមន្ត្រី

ពេជ្រ ប៊ុនធិន

**ចម្លងជូន៖**
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរនិងអង្គភាពចំណុះ
- ឯកសារ-កាលប្បវត្តិ